អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣

# សេចក្តីប្រកាសព័ត៌មាន

## លោក NICHOLAS KOUMJIAN ត្រូវបានតែងតាំងជាសហព្រះរាជអាជ្ញាអន្តរជាតិថ្មី

ក្រោយពីបានទទួលការចាត់តាំងពីលោក បាន គីមូន (Ban Ki-moon) អគ្គលេខាធិការអង្គការសហប្រជាជាតិ និងទទួលបានការតែងតាំងពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់បានតែងតាំងលោក Nicholas Koumjian (សញ្ជាតិអាមេរិក) ជាសហព្រះរាជអាជ្ញាអន្តរជាតិថ្មីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”)។

មុនទទួលបានការតែងតាំងនេះ លោក Koumjian បានធ្វើជាអគ្គរដ្ឋអាជ្ញាសាលាឧទ្ធរណ៍ដើម្បីធ្វើការចោទប្រកាន់លោក Charles Taylor អតីតប្រធានាធិបតីនៃប្រទេសលីបេរីយ៉ានៅតុលាការពិសេសសម្រាប់ប្រទេស Sierra Leone។ លោក Koumjian បានធ្វើជាមេធាវីការពារក្តីឲ្យ Abdallah Banda និង Saleh Jerbo នៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ ក្នុងរឿងក្តីដែលពាក់ព័ន្ធនឹងស្ថានភាពក្នុងទីក្រុងដាហ្វួរ និងបានផ្តល់ជំនួយផ្នែកច្បាប់ដោយស្ម័គ្រចិត្តជូនជនរងគ្រោះដែលមកពីកូតឌីវ័រ។ មុនពេលបម្រើការងារខាងលើនេះ លោក Koumjian បានធ្វើជាអគ្គរដ្ឋអាជ្ញាក្នុងការជំនុំជម្រះលោក Charles Taylor។ លោកបានដឹកនាំអង្គភាពឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលទទួលថវិកាពីអង្គការសហប្រជាជាតិនៅទីម័រខាងកើត (East Timor) និងបានធ្វើជារដ្ឋអាជ្ញានៅតុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការរដ្ឋបូស្នី (Bosnia) និងហឺតហ្ស៊ីហ្គោវីណា (Herzegovina)។ មុនចូលបម្រើការងារក្នុងឆាកអន្តរជាតិ លោក Koumjian បានធ្វើជារដ្ឋអាជ្ញានៅទីក្រុង Los Angeles សហរដ្ឋអាមេរិកអស់រយៈពេល ២០ឆ្នាំ។

ដើម្បីបានព័ត៌មានបន្ថែម សូមទាក់ទង៖

លោក Lars Olsen
មន្ត្រីទំនាក់ទំនងកិច្ចការច្បាប់
ទូរសព្ទ: +855 (0)12 488 023
Land line: +855 (0)23 861 669
Email: olsenl@un.org

លោក នេត្រ ភក្ត្រា
មន្ត្រីទទួលបន្ទុកសារព័ត៌មាន
ទូរសព្ទ: +855 (0)12 488 156
Land line: +855 (0)23 861 564
Email: neth.pheaktra@eccc.gov.kh